-ធ្វើការវាយតម្លៃអំពីគុណភាពអាវុធជាតិផ្ទុះ និង បែងចែកប្រភេទ ដើម្បីរៀបចំធ្វើពិធីកិនបំផ្លាញអាវុធជាតិផ្ទុះណាដែលមិនចាំបាច់បន្តរក្សាទុក

-ទំនាក់ទំនងជាមួយគ្រប់អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និង បណ្តាប្រទេសសំដៅស្វែងរកការគាំទ្រផ្នែកបច្ចេកទេសមធ្យោបាយ សំភារៈ និងថវិកា

-ធ្វើការឃោសនាផ្សព្វផ្សាយខ្លឹមសារច្បាប់ សំដៅធ្វើអោយប្រជាពលរដ្ឋទូទាំងប្រទេសយល់បានពីសារៈសំខាន់ និង ការកែទម្រង់គ្រប់គ្រង អាវុធជាតិផ្ទុះដើម្បីចូលរួមក្នុងការងារធានាសន្តិសុខ សុវត្ថិភាពសង្គម

ប្រការ ៣ : គណៈកម្មការជាតិកែទម្រង់ការគ្រប់គ្រងអាវុធជាតិផ្ទុះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួនសំរាប់បំពេញកិច្ចប្រតិបត្តិការនេះ ។

ប្រការ ៤ : គណៈកម្មការជាតិនេះ មានសិទ្ធិបង្កើតថ្នាក់គណនេយ្យសំរាប់ប្រើប្រាស់ថវិកាមួយដោយឡែកតាមការកំណត់ និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ និង សាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០០

## សេចក្តីសំរេចលេខ ៤២ សសរ

## ស្តីពីការបង្កើតគណៈកម្មការ រៀបចំមហាសន្និបាត

## ប៉ាក់ឡាំពិកអន្តរជាតិឆ្នាំ ២០០១

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨ ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ អូឡាំពិក សំរាប់ជនពិការកម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការរៀបចំមហាសន្និបាត ប៉ារ៉ាឡាំពិកអន្តរជាតិ ឆ្នាំ ២០០១ ដែលមានសមាសភាពដូចតទៅ :

១-ឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន
២-ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជាអនុប្រធាន
៣-ឯកឧត្តម ខ្ញឹម យ៉ិនឡេង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ជាសមាជិក
៤-ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា ជាសមាជិក
៥-ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការក្រសួងទេសចរណ៍ ជាសមាជិក
៦-ឯកឧត្តម គល់ ទិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក
៧-អ.ម ស៊ីសុវត្ថិប៉ាណារ៉ា ស៊ីវិសុធ រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាសមាជិក
៨-ឧត្តមសេនីយ៍ត្រី ហ៊ុល សន្តា តំណាងក្រសួងមហាផ្ទៃ ជាសមាជិក
៩-ឯកឧត្តម ទិន ឃិន អគ្គលេខាធិការគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ ជាសមាជិក
១០-លោក ឃិន ជៀម តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
១១-លោក ឃី វាសនា នាយកមជ្ឈមណ្ឌលជាតិ ជនពិការកម្ពុជា ជាសមាជិក
១២-លោក សួរ ផេង ( ហាងកុងសង់ព្រាណ ) ជាសមាជិក
១៣-លោក ខូច ម៉េងនី ( សណ្ឋាគារអាំងទែកុងទីណង់តាល់ ) ជាសមាជិក
១៤-លោក Chris Minko ទីប្រឹក្សាគណៈកម្មការប៉ារ៉ាឡាំពិកកម្ពុជា ជាសមាជិក

ប្រការ ២ : មហាសន្និបាតប៉ារ៉ាឡាំពិកអន្តរជាតិ ឆ្នាំ ២០០១ ត្រូវប្រារព្ធធ្វើឡើង នៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ២៥ ដល់ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០១ ។

ប្រការ ៣ : គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

-រៀបចំចាត់ចែងដំណើរការ មហាសន្និបាត អោយបានទទួលលទ្ធផលល្អជាវិជ្ជមាន .
-រៀបចំចាត់ចែង មធ្យោបាយ ការស្នាក់នៅហូបចុករបស់ភ្ញៀវ ចូលរួមមហាសន្និបាត .
-ធានាសន្តិសុខ សុវត្ថិភាព របៀបរៀបរយសំរាប់មហាសន្និបាត .
-អាចអំពាវនាវ រកជំនួយមនុស្សធម៌ ពីសប្បុរសជននានា សំរាប់កិច្ចដំណើរការនេះ
-បង្កើតអនុគណៈកម្មការមួយចំនួន ដើម្បីជាជំនួយការ តាមការចាំបាច់ ។

ប្រការ ៤ ៖ សមាជិក របស់គណកម្មការ ត្រូវអញ្ជើញចូលរួមប្រជុំតាមសំណើរបស់ប្រធាន ឬ អនុប្រធានគណៈកម្មការនេះ ។

ប្រការ ៥ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងវប្បធម៌និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គណកម្មាធិការអធិរាជ្ជ័យប្រកបប្រយោជន៍ អន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេច អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០០

**សេចក្តីសំរេចលេខ ៤៣ សសរ**
**ស្តីពីការតែងតាំងបេសកជនរបស់នាយករដ្ឋមន្ត្រី**
**នៃរាជរដ្ឋាភិបាលកម្ពុជា**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់អភិបាលខេត្តកោះកុង លេខ ៧៥៦ អកក ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០០

**សំរេច**

ប្រការ ១ ៖ តែងតាំងលោកឧកញ៉ា លី យ៉ុងផាត់ ជាបេសកជនរបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុក ការងារអភិវឌ្ឍន៍ ខេត្តកោះកុង ។